# គោលការណ៍អនុវត្តន៍ប្រកបដោយប្រសិទ្ធិភាពខ្ពស់ដើម្បីស្តារលទ្ធភាព និងបម្លាស់ទីសត្វទោច និងទោច "សៃម៉ាំង" អត្ថបទសង្ខេប ២០១៧

## អារម្ភកថា

ឯកសារនេះ គឺជាការបកស្រាយសង្ខេបនៃចំណុចសំខាន់មួយចំនួន នៅក្នុងគោលការណ៍អនុវត្តន៍ប្រកបដោយប្រសិទ្ធភាពខ្ពស់ដើម្បីស្តារលទ្ធភាព និងបម្លាស់ទីសត្វទោច(២០១៥)។ ឯកសារមួយនេះមិនត្រូវបានចាត់ទុកជាឯកសារគោល និងមិនមានបញ្ជាក់លម្អិតអំពីគោលការណណែនាំសំខាន់នោះទេ។

គោលការណ៍ណែនាំពេញលេញ នៅទីនេះ គឺមានតែក្នុងភាសាអង់គ្លេសប៉ុណ្ណោះ។ ការបកស្រាយសង្ខេបនេះ (មានបកប្រែក្នុងភាសាមួយចំនួន) គឺត្រូវបានបង្កើតឡើង ដើម្បីជួយដល់អ្នកអនុវត្តការងារដែលពាក់ព័ន្ធអាចបង្ហាញពីគោលការណ៍ណែនាំនេះទៅដល់រដ្ឋាភិបាល និងក្រុមការងារផ្សេងទៀត ដែលមិនប្រើប្រាស់ភាសាអង់គ្លេសជាភាសាទីមួយ។ ឯកសារនេះមិនអាចចាត់ទុកជាឯកសារគោលនៃគោលការណ៍ណែនាំបាននោះទេ ហើយអ្នកអនុវត្ត និងមន្ត្រីរដ្ឋាភិបាលត្រូវប្រើគោលការណ៍ណែនាំពេញលេញ (មានក្នុងភាសាអង់គ្លេស) ជាឯកសារផ្លូវការ។

ច្បាប់ចម្លងនៃគោលការណ៍អនុវត្តន៍ប្រកបដោយប្រសិទ្ធភាពខ្ពស់សម្រាប់ការស្តារលទ្ធភាព និងបម្លាស់ទីសត្វទោច (២០១៥) អាចទាញយកដោយឥតគិតថ្លៃ តាមរយៈគេហទំព័រ http://www.gibbons.asia/wpcontent/uploads/2015/05/Best-Practice-Guidelines_Gibbons_LR.pdf ។

## សេចក្តីផ្តើម

អង្គការIUCN SSC PSG និង SSA មានគោលបំណងរួមគ្នាក្នុងការសម្របសម្រួលសកម្មភាពអភិរក្សសត្វទោចនៅទូទាំងពិភពលោក។ ដោយសារសត្វទោចកំពុងទទួលរងការគម្រាមកំហែងយ៉ាងធ្ងន់ធ្ងរនៅទូទាំងតំបន់ដែលពួកគេរស់នៅ ការបម្លាស់ទីនឹងក្លាយជាសមាសធាតុដ៏សំខាន់ក្នុងកិច្ចការអភិរក្ស ដែលវាបានផ្តល់នូវការកំណត់ចំនួន ឬសគល់នៃការបំផ្លិចបំផ្លាញជាមូលដ្ឋាន និងវត្តមានសត្វទោចដែលបានត្រៀមរួចជាស្រេចសម្រាប់ការដោះលែង។

កម្មវិធីស្តារលទ្ធភាពឡើងវិញ និងបម្លាស់ទីនេះ កំពុងប្រែក្លាយទៅជាសមាសធាតុមួយ ដែលកាន់តែសំខាន់សម្រាប់ផែនការសកម្មភាពអភិរក្ស (CAP) ដើម្បីជួយដល់ពពួកសត្វដែលកំពុងទទួលរងការគម្រាមកំហែង។ ការបម្លាស់ទីនេះនឹងបកស្រាយអំពីបញ្ហាអភិរក្សទៅតាមកម្រិតខុសៗគ្នា ដោយ ទី១៖ ទោចដែលរក្សាទុកក្នុងតំបន់ហ៊ុមព័ទ្ធ ជាទូទៅ គឺជាសត្វទទួលរងគ្រោះពីការជួញដូរសត្វព្រៃខុសច្បាប់ដែលត្រូវបានចាប់យកមកពីក្នុងព្រៃ ទទួលបាននូវការជួយសង្គ្រោះ និងស្តារលទ្ធភាពឡើងវិញ និងបន្ទាប់មកក៏ត្រូវដោះលែងត្រឡប់ទៅក្នុងព្រៃវិញ ទី២៖ ដោះលែងទោចទៅក្នុងតំបន់ដែលសត្វប្រភេទនេះបានផុតពូជ ឬ ចំនួនពួកគេមិនអាចនៅស្ថិតស្ថេរយូរអង្វែង ហេតុដូច្នេះហើយ ចាំបាច់ត្រូវបង្កើនចំនួននេះឡើងវិញ(Cheyne 2005, 2009a; Kleiman 1989)។ ឧទាហរណ៍៖ កម្មវិធីដោះលែងនេះអាចផ្តល់ឱកាសបង្កើនឡើងវិញនូវចំនួន

សត្វទោចដែលបានផុតពូជតាមតំបន់(Komdeur and Deerenberg 1997)។

គោលការណ៍ណែនាំទាំងអស់នេះ ត្រូវបានបង្កើតឡើងដោយកិច្ចសហការរួមគ្នារវាងអង្គភាពមួយចំនួន ដែលធ្វើការងារពាក់ព័ន្ធនឹងការអភិរក្សអំបូរទោច។ សិក្ខាសាលាមួយត្រូវបានសម្របសម្រួលដោយអង្គការ IUCN SSC PSG និង SSA កាលពីខែមករា ឆ្នាំ២០១៤ តំណាងជាច្រើនរូបដែលមកពីគម្រោងអភិរក្ស និង ស្តារលទ្ធភាពសត្វទោច បានចូលរួមចំណែកក្នុងការអភិវឌ្ឍព្រាងនៃគោលការណ៍ណែនាំស្តីពីការអនុវត្តប្រកបដោយប្រសិទ្ធិភាពខ្ពស់នេះ។ ពង្រាងនេះត្រូវបានអនុវត្តដោយមានការពិនិត្យឡើងវិញទាំងស្រុងពីអង្គការ SSA រួមជាមួយមតិសាធារណៈ។ យោងតាមបទពិសោធ និងចំណេះដឹងដែលបានចែករំលែកមកទល់នឹងពេលនេះ គោលការណ៍ណែនាំមួយនេះត្រូវបានបង្កើតទៅជាឯកសារប្រតិបត្តិការដ៏មានសារៈសំខាន់មួយសម្រាប់អង្គភាពអនុវត្តគម្រោងទាំងអស់ប្រើប្រាស់ ក្នុងគោលបំណងបំពាក់គ្រឿងបរិក្ខាដល់គម្រោងនៅទីវាល និងអ្នកធ្វើការសម្រេចចិត្តជាមួយនឹងឧបករណ៍មួយចំនួន ដើម្បីអនុវត្តន៍សម្លេងបែបវិទ្យាសាស្រ្តក្នុងការបម្លាស់ទី និងស្តារលទ្ធភាពសត្វទោច។ ក្នុងអំឡុងសិក្ខាសាលា ស្តីពីការស្តារលទ្ធភាព ការដោះលែង និងបម្លាស់ទីសត្វទោច ឆ្នាំ២០១៤នេះដែរ បញ្ហាមួយចំនួនដែលកំណត់បាននៅក្នុងលទ្ធផលនៃការងារបម្លាស់ទីសត្វទោច រួមមាន៖ ១-ខ្វះគោលការណ៍ណែនាំច្បាស់លាស់ ដើម្បីផ្តល់នូវគោលគំនិតលើការវាយតម្លៃដែនជម្រក ការបង្កាត់ថែទាំ និងវិធីសាស្រ្តដោះលែង ២-ខ្វះដែនជម្រកដែលមានការការពារត្រឹមត្រូវ ៣-ខ្វះគោលការណ៍ត្រួតពិនិត្យសត្វក្រោយពេលដោះលែងប្រកបដោយស្តង់ដារ ៤-មិនមានយុទ្ធសាស្រ្តគ្រប់គ្រាន់ដើម្បីការពារសត្វក្រោយពេលដោះលែង ៥- ខ្វះការគាំទ្រពីរាជរដ្ឋាភិបាលក្នុងបរិបទប្រកួតប្រជែង និង ៦- ខ្វះនូវកិច្ចប្រជុំថ្នាក់ជំនាញដើម្បីចែករំលែកព័ត៌មានអំពី ភាពជាក់លាក់នៃសត្វទោច។

ឯកសារមួយនេះគឺជាការបកស្រាយសង្ខេបអំពីគោលការណ៍គន្លឹះ ដែលត្រូវបានពិភាក្សានៅក្នុងប្រធានបទ "**គោលការណ៍អនុវត្តន៍ប្រកបដោយប្រិទ្ធិភាពខ្ពស់ដើម្បីស្តារលទ្ធភាព និងបម្លាស់ទីសត្វទោច**" (Campbell et al. 2015) ។ អ្នកអនុវត្តទាំងអស់គួរផ្តោតទៅលើឯកសារដ៏សំខាន់មួយនេះ ដើម្បីទទួលបានអំណះអំណាងច្បាស់លាស់ ឬក៏ភ្ជាប់ទៅកាន់គេហទំព័ររបស់IUCNដោយផ្ទាល់ តាមមរយៈ៖ www.gibbons.asia សម្រាប់ព័ត៌មានបន្ថែម។

## ពាក្យ និងនិយមន័យ

រយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ មានការពិភាក្សាដ៏គួរឲ្យកត់សម្គាល់មួយស្តីពីនិយមន័យជុំវិញការដោះលែង និងបម្លាស់ទី (Seddon et al. 2012) ។ អំណះអំណាងមួយចំនួនត្រូវបានទាមទារឲ្យមានការពាក់ព័ន្ធទៅនឹងសត្វទោច ដោយសារគោលការណ៍ណែនាំពីមុនរបស់IUCNចំពោះការកំណត់ប្រភេទសត្វមិនមាននិយមន័យដើម្បីកំណត់សកម្មភាពទាំងអស់ដែលបង្ហាញក្នុងឯកសារនេះទេ ហើយពួកគេក៏មិនបានបង្ហាញពីគុណភាពក្នុងការអនុវត្តសកម្មភាពនៅទីតាំងផ្ទាល់ចំពោះសកម្មភាពថ្មីៗទាំងនេះផងដែរ។ វាគឺពិតជាសំខាន់ នៅពេលដែលអ្នកអនុវត្តយល់ច្បាស់ពីនិយមន័យដែលត្រូវប្រើនៅក្នុងគោលការណ៍ណែនាំនេះជាពិសេស នៅពេលដែលកំពុងដោះស្រាយបញ្ហាចោទទាំងនេះ៖ ការស្តារលទ្ធភាពឡើងវិញត្រូវបានអនុវត្ត

មុនគេ ហើយសកម្មភាពបន្តបន្ទាប់គឺ ការបម្លាស់ទី ការផ្ទេរពីព្រៃមួយទៅព្រៃមួយ និងការដោះលែងប្រកបដោយសុវត្ថិភាព។ ក្នុងឯកសារនេះ យើងកំពុងពិភាក្សាអំពីគម្រោងពីរសំខាន់ៗ៖

- គម្រោងផ្សារភ្ជាប់ជាមួយនឹងការជួយសង្គ្រោះសត្វទោចដែលមានរបួស ឬកំព្រា ដោយផ្តល់ឲ្យពួកគេនូវការស្តារលទ្ធភាពឡើងវិញ និងចុងក្រោយ ធ្វើការបម្លាស់ទីទោចទាំងអស់ដែលសមស្របចំពោះការដោះលែងទៅកាន់ជម្រកធម្មជាតិរបស់ពួកគេវិញ។
- គម្រោងផ្សារភ្ជាប់ជាមួយនឹងការផ្លាស់ទីនៃសត្វទោចនៅក្នុងព្រៃពីជម្រកមិនសមស្របទៅកាន់ជម្រកដែលសមស្រម ឧ-គម្រោងបម្លាស់ទីពីព្រៃមួយទៅព្រៃមួយផ្សេងទៀត។

មានការទទួលស្គាល់ចំពោះគោលការណ៍នេះ ប៉ុន្តែនៅបន្តធ្វើការជាមួយគោលការណ៍នៃនិយមន័យ IUCN ឆ្នាំ២០១៣ គោលការណ៍បន្ទាប់នឹងត្រូវអនុវត្តនៅក្នុងឯកសារនេះ។

តារាងទី១៖ សង្ខេបនិយមន័យដែលត្រូវប្រើក្នុងឯកសារនេះ។

| **និយមន័យ/ប្រភព** | **ពណ៌នាសង្ខេប** |
|---|---|
| ការជួយសង្គ្រោះ | ការផ្លាស់ទីពពួកពានរព្រៃចេញពីស្ថានភាពគ្រោះថ្នាក់ ឬ ការដោះស្រាយជម្លោះរវាងមនុស្ស និង ពានរ ក្នុង គោលបំណងធ្វើឲ្យការរស់នៅរបស់ពួកគេប្រសើរឡើង។ |
| ការស្តារលទ្ធភាពឡើងវិញ | ដំណើរការគ្រប់គ្រងសត្វទោចដែលបានផ្លាស់ទីជម្រក ឈឺ រងរបួស ឬ កំព្រា ឲ្យទទួលបាននូវសុខភាពល្អ និងមានជំនាញឡើងវិញ វាទាមទារការបំពេញមុខងារជាធម្មតា និង រស់នៅដោយម្ចាស់ការលើខ្លួនឯង។ |
| បម្លាស់ទី | ការផ្លាស់ទីសត្វទោច ដែលត្រូវបានដោះលែងពីតំបន់មួយទៅកាន់តំបន់មួយផ្សេងទៀត។ |
| បម្លាស់ទីបែបអភិរក្ស | បម្លាស់ទីបែបអភិរក្សគឺជាការផ្លាស់ទី និងដោះលែងសត្វទោចដែលគោលដៅចម្បងគឺការអភិរក្សដ៏មានអត្ថប្រយោជន៍៖ គោលដៅនេះនឹងជួយធ្វើឲ្យកាន់តែប្រសើរឡើងនូវស្ថានភាពអភិរក្សប្រភេទសត្វដែលពាក់ព័ន្ធសំខាន់ៗនៅតាមតំបន់ ឬនៅទូទាំងពិភពលោក និង/ឬការស្តារឡើងវិញនូវដំណើរការ ឬមុខងារនៃប្រព័ន្ធអេកូឡូស៊ីធម្មជាតិ។ |
| បម្លាស់ទីពីព្រៃមួយទៅព្រៃមួយ | ការចាប់សត្វទោចក្នុងគោលបំណងផ្លាស់ទីពីជម្រកធម្មជាតិមួយទៅជម្រកមួយផ្សេងទៀត។ |
| ការស្តារកំណើនឡើងវិញ | បម្លាស់ទីទៅក្នុងតំបន់ដែលជាប្រភពជម្រកដើម និងរួមបញ្ចូលសកម្មភាពទាំងពីរនេះ៖ ការពង្រឹង និងការដោះលែង។ |
| ការពង្រឹង | ការផ្លាស់ទី និងការដោះលែងសត្វទោច (ទោចព្រៃ ឬទោចចិញ្ចឹម) ត្រឡប់ទៅកាន់ទីតាំង ដែលមានទោចប្រភេទដូចគ្នារស់នៅ។ |
| ការដោះលែង | ការដោះលែងគឺជានាំយក និងដោះលែងសត្វទោចទៅកាន់ជម្រកដើមដែលពួកគេធ្លាប់រស់នៅពីមុន។ |
| ការដាក់បញ្ចូលអភិរក្ស | ការដាក់បញ្ចូលអភិរក្សគឺជាការផ្លាស់ទី និងដោះលែងសត្វទោចក្នុងគោលបំណងឲ្យពួកគេបានរស់នៅក្នុងទីជម្រកដើមរបស់ពួកគេវិញ។ |
| កំណែប្រែប្រព័ន្ធអេកូឡូស៊ី | កំណែប្រែប្រព័ន្ធអេកូឡូស៊ីគឺជាការផ្លាស់ទី និងដោះលែងសត្វទោចទៅកាន់ទីតាំងដើមរបស់ពួកគេ ដើម្បីដើរតួនាទីក្នុងប្រព័ន្ធអេកូឡូស៊ីជាក់លាក់មួយ។ |
| ការដោះលែងប្រកបដោយសុវត្ថិភាព | ការដោះលែងសត្វទោចចិញ្ចឹមនៅក្នុងឬក្រៅទីតាំងដើមរបស់ពួកគេ ជាកន្លែងដែលមានភស្តុតាងចង្អុលបង្ហាញថាពួកគេនឹងរស់នៅប្រកបដោយសុវត្ថិភាព។ |

## ការវាយតម្លៃបុរេលទ្ធភាព

### គោលការណ៍បង្ការ

គោលការណ៍បង្ការគឺជាមធ្យោបាយដើម្បីធ្វើការសម្រេចចិត្តក្នុងការគ្រប់គ្រងហានិភ័យ ដែលបញ្ជាក់ពីគោលការណ៍ ឬវិធានការការពារ បើទោះជាមិនមានភាពប្រាកដប្រជាផ្នែកវិទ្យាសាស្ត្រអំពីថា តើឥទ្ធិពលដែលបង្កគ្រោះថ្នាក់នឹងកើតមានឡើងឬយ៉ាងណាក៏ដោយ។ មធ្យោបាយមួយនេះគួរតែត្រូវបានទទួលយកនៅពេលធ្វើផែនការបម្លាស់ទីសត្វទោចៈ មានបន្ទុកនៃភស្តុតាងមួយបង្ហាញថា បម្លាស់ទីមិនបង្កគ្រោះថ្នាក់ដល់សត្វទោច ដែលគម្រាមកំហែងដោយជម្ងឺឆ្លង ការបង្កកំណើតដោយមិនបានព្រៀងទុក ការរំខានហួសប្រមាណពីទោចដទៃ ការធ្វើឲ្យថប់អារម្មណ៍ ការប្រកួតប្រជែងរកចំណី និងផលប៉ះពាល់ផ្សេងទៀតនោះទេ។ បម្លាស់ទីក៏បង្កផលប៉ះពាល់ផងដែរទៅដល់ពពួកសត្វទោចដែលមានទៅទីតាំងនោះស្រាប់ក្នុងការទំនាក់ទំនងទៅកាន់សត្វទោចដទៃ ឬអាចប៉ះពាល់ដល់បូរណភាពអេកូឡូស៊ីនៃតំបន់ដែលពួកគេរស់នៅ។ ការអភិរក្សសត្វទោចឲ្យមានកំណើនស្ថិតស្ថេរនៅក្នុងព្រៃ គឺចាំបាច់ត្រូវទទួលយកចំណុចជាអាទិភាពចំពោះសុខមាលភាពនៃសត្វប្រភេទនេះនៅកន្លែងចិញ្ចឹម។

### ការអភិរក្ស និង បម្លាស់ទីប្រកបដោយសុវត្ថិភាព

ដើម្បីធានាថាបម្លាស់ទីមានឥទ្ធិពលដល់ការអភិរក្ស ទោចដែលត្រូវបានធ្វើបម្លាស់ទីរួច គួរតែអាចរួមចំណែកពង្រឹងដល់ចំនួនសត្វព្រៃដែលមានស្រាប់ រួមចំណែកក្នុងការបង្កើតចំនួនសត្វព្រៃថ្មីនៅក្នុងតំបន់ភូមិសាស្ត្រដែលអំបូរទោចរស់នៅ រួមចំណែកស្តារដំណើរការឬមុខងារប្រព័ន្ធអេកូឡូស៊ីធម្មជាតិឡើងវិញ។ ឧទាហរណ៍ដូចជា ចំនួនសត្វដែលត្រូវបានធ្វើកំណើន ឬដោះលែងមិនអាចនៅស្ថិតស្ថេរយូរអង្វែងបានទេ។ ក្នុងឧទាហរណ៍មួយនេះ បម្លាស់ទី ឬការធានានូវចំនួនសត្វ អាចជាផ្នែកមួយនៃចំនួនដែលបានផ្លាស់ប្តូរដែលវាសមស្រម ដើម្បីធ្វើការបង្ហាញពីបញ្ហាដែលអាចផ្តល់នូវផលចំណេញ។

### ការគ្រប់គ្រងបម្រែបម្រួលនៃចំនួន

វាត្រូវបានណែនាំជាពិសេសអំពី គម្រោងដែលផ្សារភ្ជាប់ទៅនឹងការបម្លាស់ទីសត្វទោច ដែលនេះស្ថិតនៅក្នុងគោលគំនិតនៃការពិចារណាលើមធ្យោបាយគ្រប់គ្រងបម្រែបម្រួលនៃចំនួនសត្វទោច។ ប្រការនេះតម្រូវឲ្យមានការគ្រប់គ្រងយ៉ាងសកម្មជាមួយស្ថាប័នផ្សេង ក្នុងការផ្តល់ជម្រកដល់ទោចចិញ្ចឹមក្នុងប្រភេទតែមួយ និងក្រុមអ្នកគ្រប់គ្រងអភិរក្សជម្រកដើម ធ្វើការនៅក្នុងទីតាំងដែលមានទោចប្រភេទដូចគ្នារស់នៅ។ បណ្តាញការងារនេះ អនុញ្ញាតឲ្យការយល់ដឹងមានភាពកាន់តែច្បាស់លាស់ថែមទៀតចំពោះវិធីសាស្ត្រ ដែលសត្វទោចនីមួយៗអាចរួមចំណែកក្នុងលទ្ធផលអភិរក្សជារួម ជាជាងគ្រាន់តែយកចិត្តទុកដាក់លើលទ្ធផលបម្លាស់ទីចំពោះគម្រោង និងទីតាំងនីមួយៗ។ គោលបំណងចុងក្រោយនៃមធ្យោបាយមួយនេះនឹងប្រែក្លាយជាការរួមបញ្ចូលគ្នារវាងលទ្ធផលអភិរក្សក្នុងទីតាំងដើម និងក្រៅទីតាំងដើម ដើម្បីធ្វើឲ្យស្ថានភាពអភិរក្សកាន់តែប្រសើរឡើង។

### ការប្រើប្រាស់មូលនិធិប្រកបដោយនិរន្តភាព

ដើម្បីឲ្យគម្រោងទាំងនេះធានាបានដល់ការប្រើប្រាស់មូលនិធិរយៈពេលវែង អ្នកអនុវត្តគម្រោងចាំបាច់ត្រូវផ្សារភ្ជាប់ជាមួយភាពស្មោះត្រង់ បើកកិច្ចពិភាក្សាដោយប្រាកដប្រជាជាមួយអ្នកផ្តល់ជំនួយក្នុងដំណាក់កាលធ្វើផែនការ រួមបញ្ចូលទាំងតម្រូវការសម្រាប់គម្រោងដើម្បីគ្រប់គ្រង "មូលនិធិសង្គ្រោះ" ចំពោះថ្លៃចំណាយដែលមិនរំពឹងទុក/បម្រុងទុកមុន។ បម្រែបម្រួលដែលសមស្របក្នុងអំឡុងពេលអនុវត្តគម្រោង ដំណាក់កាលអនុវត្តគឺធ្វើឡើងជាធម្មតា ហើយថវិការគួរតែស្ថិតនៅក្នុងលក្ខខ័ណ្ឌដែលអាចគ្រប់គ្រង និង បត់បែនបាន ដើម្បីសម្រួលដល់បម្រែបម្រួលទាំងនោះ (IUCN/SSC 2013) ។ គន្លឹះដែលគួរឲ្យយកចិត្តទុកដាក់រួមមាន៖

- សកម្មភាពគម្រោង និងប្រភពមូលនិធិគួរតែត្រូវបានបែងចែក (ក្នុងផែនការមេរួមមួយ) ដូចជា ប្រសិនបើមូលនិធិសម្រាប់សកម្មភាពគម្រោងមួយបរាជ័យ គម្រោងដែលនៅសល់នឹងនៅតែដំណើរការ។
- កំណត់បុគ្គលដែលជាគោលដៅនៅក្នុងការរៀបចំមូលនិធិ ដែលបុគ្គលនោះអាចផ្តល់ដំបូន្មានអំពីការបន្តគោលដៅរបស់ម្ចាស់ជំនួយបាន។
- ធ្វើការទំនាក់ទំនងឲ្យបានញឹកញាប់ និងយ៉ាងមានប្រសិទ្ធិភាពបន្ថែមទៀតជាមួយម្ចាស់ជំនួយតាមរយៈការប្រាស្រ័យទាក់ទងល្អ ដើម្បីធានាបន្តសម្រេចគោលដៅដែលបានចែករំលែកឲ្យគ្នា បើទោះជាស្ថិតក្នុងការប្រែប្រួលក្នុងកម្រិតថេរក៏ដោយ។
- សច្ចៈភាពម្ចាស់ជំនួយតម្រូវឲ្យមានការពិភាក្សានៅពេលប្រើប្រាស់ថវិកាជំនួយ ពោលគឺ តើថវិកានោះ អាចរកបានជាថ្មីម្តងទៀតឬយ៉ាងណា? ផ្អែកតាមការបំពេញការងារយ៉ាងជោគជ័យនៃគោលដៅ ដែលបានឯកភាពគ្នាដំបូង។

## ស្ថេរភាពនៃចំនួនសត្វទោច

ប្រសិនបើគោលបំណងនៃផែនការបម្លាស់ទីធ្វើឡើងដើម្បីបង្កើតចំនួនថ្មីមួយ ដូច្នេះ វាគឺមានសារៈសំខាន់ក្នុងការបញ្ជាក់ថា នឹងមានមូលដ្ឋានគ្រប់គ្រាន់ដើម្បីធានាចំនួនសត្វទាំងនោះអាចរស់នៅបានក្នុងលក្ខខ័ណ្ឌបម្រែបម្រួលអាកាសធាតុផ្សេងៗ (ដូចជាគ្រោះធម្មជាតិ) និងអាចរក្សាប្រភេទខុសគ្នានៃហ្សែនមេបាបានយ៉ាងត្រឹមត្រូវ។ ថ្មីៗនេះ ការប៉ាន់ស្មានពីកំណើនថេរក្នុងកម្រិតតិចបំផុតមួយនៅក្នុងចំណោមសត្វទោច ដែលបានដោះលែងគឺមិនអាចធ្វើទៅបាននោះទេ។ ប៉ុន្តែ ក្នុងកាលៈទេសៈនេះ សត្វទោនឹងមិនអាចទទួលយកនូវលក្ខខ័ណ្ឌរស់នៅណាមួយ ក្នុងពេលតែមួយដើម្បីធ្វើឲ្យចំនួនពួកគេនៅថេរបានឡើយ។ ការធ្វើឲ្យកំណើននៅថេរក្នុងកម្រិតទាបបំផុតមួយ អាចសម្រេចទៅបាន តាមរយៈក្រុម ដែលបម្លាស់ទីដោយជោគជ័យ និង/ឬ ដំណើរការបង្កាត់ពូជតាមធម្មជាតិ និង/ឬ ការធានាបានថា ចំនួននោះអាចជាផ្នែកនៃបម្រែបម្រួលចំនួនសត្វទោចទាំងអស់។

## ការវាយតម្លៃផ្នែកច្បាប់

### ការរួមចំណែករបស់អាជ្ញាធរក្នុងតំបន់

ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការធ្វើបម្លាស់ទី ដែលត្រូវបានស្នើសុំគឺមានសារៈសំខាន់ណាស់។ ផ្អែកលើស្ថានភាពនៃទីតាំងដោះលែងដែលបានជ្រើសរើស ការចូលរួមរបស់អាជ្ញាធរក្នុងតំបន់នឹងមានភាព

ខុសគ្នា។ ប៉ុន្តែ កម្មវិធីបម្លាស់ទីនីមួយៗនឹងនៅតែទាមទារការអនុញ្ញាតពីភ្នាក់ងាររាជរដ្ឋាភិបាលដែលពាក់ព័ន្ធ។ គោលការណ៍របស់រាជរដ្ឋាភិបាលក្នុងការធ្វើបម្លាស់ទីអាចនឹងធ្វើឡើងខុសៗគ្នា ហើយវាពិតជាសំខាន់ក្នុងការយកចិត្តទុកដាក់ទៅលើបញ្ញត្តិ និងច្បាប់ថ្នាក់អន្តរជាតិ ថ្នាក់ជាតិ និងថ្នាក់ខេត្ត ដើម្បីធានានូវមូលដ្ឋានច្បាប់សម្រាប់ការធ្វើបម្លាស់ទី និងធានាបានថា ការអនុញ្ញាតដ៏សមស្របនឹងត្រូវបានផ្តល់ឲ្យជាអាទិភាពដើម្បីបន្តដំណើរការមួយនេះ(Beck, et al., 2007) ។

## ការប្រើប្រាស់ដីធ្លី និងផែនការប្រើប្រាស់ដីធ្លី

អំណះអំណាងមួយចំនួនអំពីភាពអចិន្ត្រៃយ៍នៃទីតាំងដែលត្រូវបានជ្រើសរើសសម្រាប់គម្រោងបម្លាស់ទីគួរតែត្រូវបានទទួលយកមុននឹងការបម្លាស់ទីត្រូវបានធ្វើឡើង ដើម្បីជៀសវាងការខ្វះខ្វាយថវិកាសម្រាប់ការអភិរក្ស និងការខាតបង់ធនធានបន្តពូជ។ ផែនការប្រើប្រាស់ដីធ្លីដែលត្រូវបានស្នើនាពេលបច្ចុប្បន្នសម្រាប់ទីតាំងដោះលែងដែលត្រូវបានស្នើសុំគួរតែត្រូវបានសិក្សាស្រាវជ្រាវ និងពិភាក្សាជាមួយនឹងអាជ្ញាធរដែលពាក់ព័ន្ធ។ ទីតាំងដោះលែងមួយគួរតែអាចផ្តល់នូវទីជម្រកដែលមានសុវត្ថិភាពរយៈពេលវែង ជាមួយនឹងសក្តានុពលដែលមានដែនកំណត់សម្រាប់ការកាត់បន្ថយទំហំ ការរុករានដី ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ឬការផ្លាស់ប្តូរសំខាន់ៗនៅជុំវិញតំបន់ ដោយសកម្មភាពទាំងនេះ។ ទោះយ៉ាងណាក៏ដោយ ការថែទាំប្រកបដោយស្តង់ដារត្រឹមត្រូវតម្រូវឲ្យទីតាំងដោះលែង ដែលពុំមានការគាំទ្រណាមួយនោះ ត្រូវបានវាយតម្លៃយ៉ាងហ្មត់ចត់ជាមួយនឹងអំណះអំណាងសមហេតុផលចំពោះការការពាររយៈពេលវែង។

## ការវាយតម្លៃទីតាំងដោះលែង

ការជ្រើសរើសទីតាំងសមស្របមួយគឺជាគន្លឹះក្នុងការធ្វើផែនការបម្លាស់ទី (IUCN SSC 2013) ។ កង្វះការថែទាំប្រកបដោយស្តង់ដារក្នុងតំបន់នៃផែនការនេះ អាចបង្ហាញលទ្ធផលបរាជ័យចំពោះគម្រោងដោយហេតុផលមួយចំនួន។ វាក៏អាចលេចចេញជាលទ្ធផលដែលបង្កការខូចខាតទៅដល់ឥទ្ធិពលនៃការអភិរក្សរយៈពេលវែងច្រើនជាងនោះចំពោះសត្វទោចនីមួយៗ ប្រសិនបើការបម្លាស់ទីត្រូវធ្វើឡើងចំពោះប្រភេទសត្វដែលមិនមានដើមកំណើតទៅតំបន់នោះ។

- បំពេញតម្រូវការទាំងផ្នែកមានជីវិត និងឥតជីវិតទៅដល់ប្រភេទសត្វដែលត្រូវបានធ្វើបម្លាស់ទី។
- ត្រូវបានការពារយ៉ាងត្រឹមត្រូវ ហើយការគម្រាមកំហែងត្រូវបានត្រួតពិនិត្យ ឬគ្រប់គ្រង។
- មានទីជម្រកគ្រប់គ្រាន់តាមតម្រូវការ តាមរដូវកាល និង
- មានទំហំធំល្មម ឬមានទំនាក់ទំនងសមស្របដើម្បីគាំទ្រដល់ចំនួនសត្វឲ្យនៅថេរ (ឬយុទ្ធសាស្ត្រគ្រប់គ្រងបម្រែបម្រួលចំនួនសត្វត្រូវបានបង្កើតឡើង)។

## ការស្តារលទ្ធភាពឡើងវិញ

### ជម្ងឺដង្កាត់

សត្វទោចគួរតែទទួលការធ្វើតេស្តព្យាបាល ដែលជាផ្នែកដ៏សំខាន់មួយ ធ្វើឡើងនៅពេលមកដល់មជ្ឈមណ្ឌលជាលើកដំបូង និងអំឡុងពេលដែលពួកគេរស់នៅទីនោះដើម្បីធានាថា ជម្ងឺផ្សេងៗមិនត្រូវបានចម្លងទៅកាន់ទោចដទៃដែលនៅក្នុងទ្រុង ហើយក៏មិនមានឆ្លងទៅសត្វព្រៃដទៃទៀត តាមរយៈកម្មវិធី

ដោះលែងផងដែរ។ មិនមានទោចណាមួយគ្មានផ្ទុកនូវបាក់តេរី ឬប៉ារ៉ាសិតទាំងស្រុងនោះទេ និងដូចជាការវាយតម្លៃហានិភ័យនៃជម្ងឺនេះដែរ គួរតែធ្វើឡើងក្នុងដំណាក់កាលធ្វើផែនការ និងមានការពិនិត្យឡើងវិញម្តងហើយម្តងទៀត(IUCN/SSC 2013)។

ចំណុចដែលត្រូវអនុវត្តដើម្បីទទួលបានប្រសិទ្ធិភាពខ្ពស់៖

- ទីតាំងពិនិត្យសុខភាពដាច់ដោយឡែក និងជាក់លាក់មួយសម្រាប់ការមកដល់ដំបូង។
- ជម្រកដាច់ដោយឡែកសម្រាប់ទោចដែលមានសុខភាពល្អរស់នៅរយៈពេលយូរ។
- ជម្រកដាច់ដោយឡែកសម្រាប់ប្រភេទដែលបង្ហាញរោគសញ្ញានៃជម្ងឺ ឧ- របេងTB វីរុសវីត្រូជាដើម ដែលត្រូវកម្ចាត់ចេញពីសត្វទោចឲ្យទទួលបានសុខភាពល្អ និងចេញពីទីតាំងពិនិត្យសុខភាព។
- ទំនាក់ទំនងជាមួយនឹងមនុស្សគួរតែរក្សានៅកម្រិតតិចតួចបំផុតដើម្បីបញ្ចៀសពីការឆ្លងជម្ងឺ។
- តម្រូវឲ្យប្រើស្រោមដៃ និងម៉ាស់ និងណែនាំឲ្យមានវ៉ែនតាការពារ ស្បែកជើងកវែង និងធុងទឹកជម្រះបាតជើងពីមេរោគឆ្លង ជាមធ្យោបាយការពារពីការឆ្លងជម្ងឺ ជាពិសេសគឺនៅទីតាំងពិនិត្យសុខភាព ឬក៏តំបន់ ដែលមានសត្វទោចឈឺ។
- ជម្ងឺរបេងដែលជាញឹកញាប់កើតមានតែលើមនុស្ស ក្នុងតំបន់មួយចំនួន សត្វទោចក៏ត្រូវបានរកឃើញមានឆ្លងមេរោគនេះផងដែរ ហើយការពិនិត្យរកមេរោគនេះចំពោះបុគ្គលិកអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្ការ និងគ្រប់គ្រងជម្ងឺមួយនេះដែរផង។ បុគ្គលិកគួរតែត្រូវបានត្រួតពិនិត្យយ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ។ ក្នុងករណីសង្ស័យលើទោចណាមួយថាមានផ្ទុកវីរុសរបេង ម៉ាស់វះកាត់ស្តង់ដារមិនអាចមានប្រសិទ្ធិភាពក្នុងការបង្ការពីការស្រូបយកដំណក់សារធាតុចម្លងជម្ងឺរបេង តាមរយៈដង្ហើមបានទេ ព្រោះម៉ាស់ទាំងនោះ មួយចំនួនរចនាឡើងដោយមិនអាចបិទបាំងមុខបានជិតល្អ និងមិនអាចចម្រោះដំណក់សារធាតុចម្លងជម្ងឺរបេងទុកដោយឡែកបាន។ ប៉ុន្តែ ណែនាំឲ្យប្រើម៉ាស់ប្រភេទ N95 ជំនួសវិញ។
- បុគ្គលិកដែលមានទំនាក់ទំនងនឹងសត្វទោចគួរតែត្រូវបានត្រួតពិនិត្យសុខភាព និងព្យាបាលមេរោគឆ្លងឲ្យបានទាន់ពេលផងដែរ។ បុគ្គលិកដែលរកឃើញថាមានរោគសញ្ញានៃជម្ងឺណាមួយ មិនគួរពាក់ព័ន្ធជាមួយនឹងសត្វទោច ឬបុគ្គលិកដទៃនោះទេ។ រោគសញ្ញាទាំងនោះរួមមាន មិនត្រឹមតែរាគរូស ឈឺពោះ មេរោគឆ្លងដោយទឹកនោម ជម្ងឺស្បែក ដំបៅបើក រោគសញ្ញាផ្លូវដង្ហើមនោះទេ នៅមានរោគសញ្ញាដទៃផ្សេងទៀតផងដែរ។
- កាកសំណល់ដែលអាចចម្លងមេរោគគួរតែទុកដាក់ឲ្យបានត្រឹមត្រូវ ដើម្បីធានាកុំឲ្យមានហានិភ័យនៃការឆ្លងរោគ។

**ការតុបតែងទ្រុងសមស្របតាមឥរិយាបថ (Enrichment)**

នៅក្នុងទ្រុង/តំបន់ហ៊ុមព័ទ្ធគួរតែផ្តល់នូវបរិស្ថានធម្មជាតិឲ្យបានគ្រប់គ្រាន់ ដែលអាចឲ្យសត្វទោចបង្ហាញនូវឥរិយាបថតាមបែបធម្មជាតិរបស់ពួកគេបានច្រើនតាមដែលអាចធ្វើទៅបាន។ ដូច្នេះ វាអាចធ្វើឲ្យការអង្កេតដែលគួរឲ្យជឿទុកចិត្តត្រូវបានធ្វើឡើង ដើម្បីឲ្យមានស្ថេរភាពដល់ការបម្លាស់ទីបែបអភិរក្ស។ វិធីសាស្ត្រជាក់ស្តែងដែលធ្វើឡើង ភាគច្រើនគឺដាក់វត្ថុផ្សេងៗនៅក្នុងទ្រុង/តំបន់ហ៊ុមព័ទ្ធ ដើម្បីឲ្យសត្វទោច

តោង និង បញ្ចេញសកម្មភាពយ៉ាងមានលំនឹង ដូចជាមែកឈើ ខ្សែពួរ និងកង់សម្រាប់យោលជាដើម។ មែកឈើបានសម្រួលដល់ការបំពេញនូវសកម្មភាពនៃអំបូរ/ប្រភេទមួយ(Reinhardt and Smith 1988)៖ ក្នុងករណី ដែលទោចទាំងអស់នោះបានតោង យោល និងអង្គុយពីលើ។ ទុយោ ឬដើមឬស្សីអាចប្រើជាជម្រើសមួយផ្សេងទៀតជំនួសឲ្យមែកឈើ (Reinhardt and Smith 1988) ហើយបាវក្រណាត់ក៏អាចចងព្យួរធ្វើជាអង្រឹងសម្រាប់ដេកផងដែរ (Dickie 1994)។ វត្ថុធ្វើដោយដៃ ដែលល្អបំផុតគឺជាប្រភេទ ដែលអាចឆ្លើយតបទៅនឹងសកម្មភាពរបស់សត្វទោច ជាមួយនឹងសកម្មភាពដែលមិនអាចព្យាករណ៍បានរបស់វា (Carlstead et al. 1991) ។ ឧទាហរណ៍៖ កង់ព្យួរដែលអាចយោលចុះឡើងនៅពេលដែលទោចចាប់តោងវា នោះគឺជាប្រភពនៃ Enrichment។ (Hebert and Bard 2000)៖ បានចងក្រងនូវបញ្ជីនៃការធ្វើ Enrichment ដែលបង្ហាញនូវលទ្ធផលនៃការប្រែប្រួលឥរិយាបថជាវិជ្ជមានរបស់អំបូរពានរ ដែលរួមមាន៖

- គ្រោងឬស្សីក្រាស់
- ដើមឈើដែលគ្មានឬស
- វត្ថុថ្មី/ប្លែក
- វត្ថុលេងជាប្រភេទអាហារ
- ទោង
- វត្ថុសម្រាប់កាន់/តោង។

## ការជ្រើសរើសទោចដើម្បីដោះលែង

### ការពិនិត្យជម្ងឺ

ការគ្រប់គ្រងបសុព្យាបាល និងពិធីការដាក់នៅដាច់ដោយឡែកដែលមានមូលដ្ឋានត្រឹមត្រូវគួរតែត្រូវបានត្រួតពិនិត្យក្នុងដំណាក់កាលស្តារលទ្ធភាពឡើងវិញជាមួយនឹងថ្នាំបង្ការ និងការពិនិត្យសុខភាពមុននឹងដោះលែង។ វិធីសាស្ត្រដែលល្អ បសុពេទ្យ អ្នកបច្ចេកទេសខាងបសុព្យាបាល ឬពេទ្យសត្វ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ត្រូវមានការពាក់ព័ន្ធនៅក្នុងការជ្រើសយកសត្វនីមួយៗ ដែលសមស្រមសម្រាប់ធ្វើបម្លាស់ទី ឬដោះលែង។ ការចម្លងជម្ងឺទៅកាន់ក្រុមពានរដែលមាននៅតំបន់ដោះលែងតាមរយៈលទ្ធផលនៃការបម្លាស់ទី វាមានសក្តានុពលក្នុងការធ្វើអាព្យាក្រិតភាពតម្លៃនៃការអភិរក្សរបស់កម្មវិធីនេះ ដែលបង្កជាហានិភ័យដល់ក្រុមសត្វប្រភេទដូចគ្នា និងសត្វដទៃផងដែរ។ ដោយទទួលស្គាល់ថាការយល់ដឹងរបស់ពួកយើងអំពីជម្ងឺ ដែលកើតចំពោះអំបូរសត្វទោច បើធៀបទៅគឺនៅមានកម្រិតទាបនៅឡើយ ពួកយើងត្រូវជឿជាក់ថា អំបូរពានរអាចចាត់ទុកដូចជាអាងស្តុកទឹកមួយដែលអាចចម្លងមេរោគទៅមនុស្ស ឬផ្ទុយមកវិញមនុស្សអាចចម្លងទៅពួកគេ។

ពិធីការធ្វើបសុព្យាបាលដែលបានកំណត់យ៉ាងច្បាស់លាស់ទាំងនោះ គួរតែត្រូវបានអនុវត្តទៅលើការបញ្ជាប់ ឬ អនុម័តលើការវិភាគអំពីហានិភ័យ។ ដោយសារតែពិធីការនេះអាចមានតម្លៃខ្ពស់ ហើយក្នុងករណីមួយចំនួន វាមានដំណើរការយូរផងនោះ ធាតុមួយនេះគួរតែត្រូវបានរួមបញ្ចូលទៅក្នុងផែនការបម្លាស់ទី និងការគ្រប់គ្រងហិរញ្ញវត្ថុ។ គោលការណ៍វិភាគអំពីហានិភ័យដូចជាការវិភាគ Stoplight Hazard Analysis ដែលបានគូសបង្ហាញ ខាងក្រោម គួរត្រូវបានប្រើប្រាស់ដើម្បីធានាថា ទោចដែលចាត់ទុកថាមានលក្ខខ័ណ្ឌ

សមស្របសម្រាប់ធ្វើបម្លាស់ទី គឺមិនមានមេរោគបង្កជាជម្ងឺ ដែលផ្តល់ជាហានិភ័យដល់ទោចដែលរស់នៅតំបន់នោះស្រាប់ ឬកាត់បន្ថយលទ្ធភាពដែលអាចរស់រានបានរបស់ទោចដែលត្រូវបានដោះលែងនោះទេ។

**ការវាយតម្លៃអំពីផ្លូវអារម្មណ៍ និងឥរិយាបថ**

ទោចគួរតែត្រូវបានកំណត់ច្បាស់អំពីអាវៈយវៈ និងឥរិយាបថដែលសមស្របសម្រាប់ការដោះលែងជាអាទិភាព ដើម្បីផ្ទេរទៅកាន់តំបន់ហ៊ុមព័ទ្ធមួយដែលអាចឲ្យពួកគេបន្សុំាទៅនឹងបរិយាកាសថ្មី។ ជាថ្មីម្តងទៀត ពួកគេនឹងត្រូវបានកំណត់អំពីឥរិយាបថពួកគេក្នុងដំណាក់កាលមួយនេះ ដើម្បីប្រកដថាពួកគេអាចទទួលបានច្រកចេញពីទ្រុងដោះលែង និងត្រឡប់ទៅក្នុងព្រៃបានដោយសុវត្ថិភាព (Cheyne 2009b; Cheyne et al. 2008, 2012) ។

ការផ្ទេរទៅកាន់បរិស្ថានថ្មីអាចបង្ហាញនូវលទ្ធផលល្អ ក្នុងការកើតឡើងជាថ្មីម្តងទៀននៃឥរិយាបទអវិជ្ជមានដែលធ្លាប់បង្ហាញពីមុន ដូចជាការបម្លាស់ទីនៅលើដី ការផ្អាកឬបញ្ឈប់នូវសម្លេងយំហៅគ្នា និងឥរិយាបថមិនប្រក្រតីផ្សេងទៀត (A. Ario, pers. comm. 2013) ។ ឥរិយាបថទាំងនេះអាចកើតឡើងដោយសារតែភាពស្មុគស្មាញនៃអារម្មណ៍អាស្រ័យដោយមជ្ឈដ្ឋានរស់នៅថ្មី ប៉ុន្តែ វាក៏អាចជាសញ្ញាណបង្ហាញនូវផលវិបាកមួយក្នុងការទទួលយកនូវមជ្ឈដ្ឋានថ្មី និងការវាយតម្លៃដែលគួរឲ្យប្រុងប្រយ័ត្នមួយ ដែលនឹងត្រូវធ្វើឡើងជាអាទិភាពសម្រាប់ការដោះលែង។

ទោចដែលត្រូវបានជ្រើសរើស ដើម្បីធ្វើការបម្លាស់ទីគួរតែបង្ហាញឥរិយាបទ ដែលចាំបាច់សម្រាប់ការរស់រាន និងបន្តពូជនៅក្នុងព្រៃ។ ឥរិយាបថទាំងនោះរួមមានការចាប់តោងយ៉ាងស្ទាត់ជំនាញ ចំណូលចិត្តប្រើប្រាស់(ចាប់តោង)ផ្នែកខាងលើនៃទ្រុង ចំណង់ចំណូលចិត្តចំពោះស្លឹកឈើ/ផ្លែឈើព្រៃ និងរក្សាការរួមរស់ជាគូ(មួយនឹងមួយ)ជាវិជ្ជមាន (ឧ-សម្អិតសម្អាងខ្លួន លេង ច្រៀង និងពាក់គ្នា) (Cheyne et al. 2008, 2012; Smith 2010)។ សត្វទោចគួរតែមានសមត្ថភាពការពារខ្លួន និងគេចពីការគម្រាមកំហែង (ឧ-ការយំបន្ទរជាសម្លេងជាស់តឿនគ្នា ដើម្បីគេចចេញពីសត្វកាចសាហាវ) ។ ទោចទាំងនោះគួរតែជាទោចពេញវ័យ និងគ្រប់អាយុបង្កកំណើត ហើយ ពួកគេគួរតែជាផ្នែកមួយនៃគ្រួសារឬគូដែលមានចំណងស្អិតរមួត ឬក៏ក្នុងករណីដោះលែង ពួកគេបានបង្ហាញនូវទំនាក់ទំនងសង្គមជាវិជ្ជមានជាមួយនឹងទោចផ្សេងទៀត។

សត្វទោចមិនគួរចំណាយពេលឬផ្លាស់ទីនៅលើដីក្នុងទីតាំងហ៊ុមព័ទ្ធនោះទេ ដោយសារតែប្រការនេះទំនងជាអាចបង្កើននូវហានិភ័យក្នុងការប្រមាញ់ពីសត្វសាហាវ។ ទីតាំងហ៊ុមព័ទ្ធ ជារឿយៗ គួរតែត្រូវបានសង់ឡើងក្នុងមធ្យោបាយមួយដែលមិនលើកទឹកចិត្តដល់ឥរិយាបថបែបនេះ ហើយប្រសិនបើឥរិយាបថនេះកើតមានបន្ទាប់ពីការដោះលែង វាគួរតែត្រូវបានគ្រប់គ្រងដោយប្រើវិធីបង្អាក់។ ទោចដែលនឹងត្រូវដោះលែងគួរតែទទួលបានរបបអាហារធម្មជាតិគ្រប់គ្រាន់ជាអាទិភាព ដើម្បីទទួលបានការដោះលែងសមស្របមួយ និងអាចកំណត់ដឹងនូវប្រភពទឹកបានច្បាស់លាស់។

បញ្ហាសំខាន់ៗដែលកំពុងប្រឈមចំពោះសត្វទោចដែលត្រូវស្តារលទ្ធភាពឡើងវិញគឺ ខ្វះខាតនូវភាពរឹងមាំនៃកាយសម្បទា និងសមត្ថភាពបម្លាស់ទីរបស់ពួកគេ ទំនោរសត្វទោចដែលត្រូវដោះលែងគឺការចាកចេញពីដៃគូពួកគេ និងបញ្ហាការរកចំណី។ យោងតាមការសិក្សាស្រាវជ្រាវអំពីទោចព្រៃបានបង្ហាញថា ពួកគេបង្ហាញខ្លួន ដើម្បីស្វែងយល់បានទូលាយពីប្រភពចំណីអាហាររបស់ពួកគេ ហើយប្រការនេះមិនអាចទៅរួច

សម្រាប់សត្វដែលត្រូវដោះលែងនោះទេ ជាពិសេសគឺសត្វចិញ្ចឹមនៅក្នុងទ្រុង ដែលពួកគេមិនទាន់ដឹងពីវិធីសាស្ត្រស្វែងរកចំណីនៅឡើយ។ ទោះយ៉ាងនេះក្តី វាអាចនឹងមានការលំបាកក្នុងការផ្តល់នូវមជ្ឈដ្ឋានរស់នៅថ្មីមួយដល់សត្វទោចដែលមិនធ្លាប់រស់នៅក្នុងព្រៃ។ ពួកគេត្រូវការការត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់។

## ការបម្លាស់ទីបែបអតិរេក

## ការរៀបចំទីតាំងដោះលែង

ទីតាំងដោះលែងគួរតែត្រូវបានរៀបចំយ៉ាងត្រឹមត្រូវ ដើម្បីសម្រួលដល់ការត្រួតពិនិត្យទោចដែលត្រូវបានដោះលែងបានល្អប្រសើរ។ ទីតាំងដោះលែងគួរតែមានភ្ជាប់នូវផែនទី និងការកំណត់ព្រំប្រទល់។ យោងតាមលក្ខខ័ណ្ឌភូមិសាស្ត្រ ការសាងសង់ប្រព័ន្ធផ្លូវលំអាចតម្រូវឲ្យមាន ដើម្បីដំណើរការច្រកចូលកាន់តែងាយស្រួលថែមទៀត និង ជម្រុញដល់ការកត់ត្រា និងទំនាក់ទំនងព័ត៌មានក្រោយពីដោះលែងកាន់តែមានភាពត្រឹមត្រូវច្បាស់លាស់។ ហេដ្ឋារចនាសម្ព័ន្ធ ដែលនៅក្បែរមួយចំនួនក៏ជាតម្រូវការមួយដើម្បីសម្រួលដល់បុគ្គលិក ក៏ដូចជាដើម្បីតំណភ្ជាប់បណ្តាញអគ្គិសនី ទឹក និងប្រព័ន្ធទំនាក់ទំនង និង ទ្រុងបន្សាំសម្រាប់ទោចផងដែរ។

## ទ្រុងបន្សាំ

ទ្រុងបន្សាំប្រើក្នុងគោលបំណងអនុញ្ញាតឲ្យទោចទទួលដឹងពីបរិស្ថានថ្មី ក៏ដូចជាការវាយតម្លៃទៅលើឥទ្ធិពលជ្រៀតជ្រែកពីទោចឬសត្វដទៃ។ ទ្រុងបន្សាំទាំងនោះគួរតែមានទំហំធំល្មម ដែលអាចឲ្យទោចសម្តែងនូវសកម្មភាពជាប្រក្រតី ហើយវាកាន់តែប្រសើរថែមទៀត ប្រសិនបើធំជាងទ្រុងពីមុនរបស់ពួកគេ ប៉ុន្តែជារឿយៗ វាមិនអាចធ្វើទៅបានដោយសារតែកត្តាភូមិសាស្ត្រនៃទីតាំងដោះលែង។ វាក៏សំខាន់ផងដែរប្រសិនបើទ្រុងមានទំហំធំល្មម ដែលអាចសម្រួលដល់ការពន្យារដោះលែងដោយមិនបានព្រាងទុក។

ការផ្តើមឡើងនូវការឃុំបន្ទរជាប្រក្រតីគឺជាការចង្អុលបង្ហាញទូទៅថា ទោចទាំងនោះមានភាពសុខស្រួលផ្នែកអារម្មណ៍នៅក្នុងបរិស្ថានថ្មីរបស់ពួកគេ និងបង្ហាញនូវឥរិយាបថជាគន្លឹះផ្សេងទៀត ដែលយើងចង់បាន បន្ទាប់មកការដោះលែងពីក្នុងទ្រុងបន្សាំនឹងត្រូវធ្វើឡើងយ៉ាងសមស្រប។ ការឃុំបន្ទរក៏នឹងជួយកំណត់ថាតើទោចឬសត្វដទៃ ដែលរស់នៅក្បែរនោះទំនងជានឹងបង្ហាញពីការប្រកួតប្រជែងកំណត់ដែនដី ពេលដែលទោចត្រូវបានដោះលែងឬយ៉ាងណា។

## សង្ខេបបម្លាស់ទី

បញ្ហាចោទខាងក្រោមមានប្រសិទ្ធិភាពជាពិសេសចំពោះការបម្លាស់ទី ដែលត្រូវបានកំណត់យ៉ាងច្បាស់នៅទីនេះថាជាការចាប់ដោយគ្មានការព្រៀងទុក និងចលនាផ្លាស់ទីរបស់ទោចព្រៃពីជម្រកធម្មជាតិមួយទៅជម្រកមួយផ្សេងទៀត។ ការបម្លាស់ទីនេះដែរគាំទ្រដល់គោលការណ៍ណែនាំដែលត្រូវបានចុះបញ្ជីក្នុងឯកសារនេះពីមុន ឧ-ការវាយតម្លៃពីការគម្រាមកំហែង ទីតាំងនិងជម្រក ការការពារ និងការត្រួតពិនិត្យក្រោយដោះលែង ប៉ុន្តែការចាប់យកទោចព្រៃចេញត្រូវធ្វើឡើងប្រកបដោយហេតុផលត្រឹមត្រូវគ្រប់គ្រាន់។

បន្ថែមពីនេះ កិច្ចខិតខំប្រឹងប្រែងទាំងអស់គួរតែត្រូវធ្វើឡើង ដើម្បីបម្លាស់ទីក្រុមទោចទាំងមូលជាមួយគ្នា ជៀសវាងការរំខានដល់ការភ្ជាប់ទំនាក់ទំនងសង្គម និងការបង្កឲ្យថប់អារម្មណ៍បន្ថែម។

ផែនការបម្លាស់ទី ជាទូទៅ ត្រូវបានគេយកចិត្តទុកដាក់ខ្ពស់អាស្រ័យដោយ ធាតុពិត សត្វទោចទទួលរងការជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរពីការបាត់បង់គុណភាពព្រៃឈើ អាស្រ័យដោយធម្មជាតិនៃការរស់នៅលើដើមឈើរបស់ពួកគេ។ បញ្ហាដែលជះឥទ្ធិពលដល់សត្វទោចរួមមាន៖ ១-ការបាត់បង់ជម្រក (ឧ-ដោយការកាប់ព្រៃឈើ) ២-ការរស់នៅដាច់ពីគេ (ឧ-ទោច/គ្រួសារទោចនៅជាប់នឹងដើមឈើតូចៗមួយចំនួន) ៣-ការបែកខ្ញែក៖ ទោចត្រូវបង្ខំចិត្តបម្លាស់ទីនៅលើដីផ្ទាល់ក្នុងការទៅដល់ព្រៃឈើនៅផ្នែកផ្សេងទៀត ដើម្បីស្វែងរកអាហារបានគ្រប់គ្រាន់ ដែលប្រការនេះធ្វើឲ្យពួកគេងាយទទួករងគ្រោះពីការប្រមាញ់របស់សត្វសាហាវ និងបង្កជាជម្លោះរវាងមនុស្ស និងទោច។ ការបែកខ្ញែកនេះក៏អាចនាំទៅរកហានិភ័យនៃការខ្វះចំណីអាហារគ្រប់គ្រាន់ ដែលអាចបង្កើនមេរោគ/បាក់តេរីបង្កជាជម្ងឺនៅក្នុងទីតាំងដែលមានមនុស្សរស់នៅ ហើយចំនួនទោចនឹងធ្លាក់ចុះរយៈពេលវែងមួយតាមរយៈចំនួនដ៏តិចតួច និងដំណើរការកើតឡើងដោយចៃដន្យ។

## សង្ខេបការត្រួតពិនិត្យក្រោយដោះលែង

### ការប្រមូលទិន្នន័យផ្លាមៗបន្ទាប់ពីការដោះលែង/ការបំពេញបន្ថែម

ទោចត្រូវបានកំណត់ទីតាំងបន្ទាប់ពីដោះលែងរួច ដោយធ្វើការសិក្សាពីគម្រូផ្លូវនៃដែនជម្រករបស់ពួកគេ និងតាមដានពួកគេទៅកាន់កន្លែងដែលអាចមើលឃើញពួកគេដេកនៅពេលយប់។ ការយំបន្ទររបស់ប្រភេទសត្វមួយចំនួនក៏អាចនឹងត្រូវបានប្រើដើម្បីប៉ាន់ស្មានពីកន្លែងដែលក្រុមទោចកំពុងស្ថិតនៅ ប៉ុន្តែទោចច្រើនគូមិនច្រៀងជារៀងរាល់ថ្ងៃនោះទេ ដូច្នេះវិធីសាស្ត្រមួយនេះគឺនៅមានកម្រិត។ (Brockelman and Ali 1987; Brockelman and Srikosamatara 1993; Cheyne et al. 2007; Hamard et al. 2010; Nijman and Menken B.J. 2005)។ ដោយសារតែទោចមានទម្លាប់យំបែបនេះ វាត្រូវបានគេរំពឹងថា ឆ្លងកាត់ពេលវេលាដ៏ខ្លីមួយ យើងអាចដឹងពីទីតាំងជ្រកកោន និងផ្លូវធ្វើដំណើរប្រចាំថ្ងៃនៃទោច ដែលត្រូវបានដោះលែង។ ការត្រួតពិនិត្យក្រោយដោះលែងរួមបញ្ចូលនូវការប្រមូលទិន្នន័យអំពីឥរិយាបថ ដែនជម្រក អេកូឡូស៊ី ការភ្ជាប់ទំនាក់ទំនងរវាងពួកគេ និងអំពីអន្តរកម្មដែលទោចមានជាមួយនឹងទោច ឬសត្វដទៃនៅក្នុងតំបន់ដោះលែង ឧ-ស្វា និងសត្វស្លាបជាដើម។

យើងស្នើអនុវត្តន៍ការត្រួតពិនិត្យក្រោយដោះលែងក្នុងកម្រិតទាបបំផុតមួយតាមតារាងពេលខាងក្រោម៖

| មធ្យោបាយ | រយៈពេល | កំណត់សម្គាល់ |
|---|---|---|
| ការអង្កេតមើលឥរិយាបថផ្ទាល់ | ៤ខែដំបូង | ផ្តល់ចំណីបន្ថែមក្នុងអំឡុងពេលនេះជាពិសេស។ ចំណីទាំងនេះនឹងត្រូវកាត់បន្ថយដើម្បីធានាថា ទោចអាចស្វែងរកចំណីបានគ្រប់គ្រាន់ដោយខ្លួនពួកគេផ្ទាល់នៅក្នុងទីតាំងដោះលែង។ |
| ទិន្នន័យអំពីទីតាំងនៃទោចក្នុងគូនីមួយៗ | ៥ទៅ១២ខែ | ការត្រួតពិនិត្យនឹងធ្វើឡើងកាន់តែញឹកញាប់ថែមទៀតនៅពេល ដែលរដូវកាលមានការប្រែប្រួល ដើម្បីធានាបានថា ទោចទាំងនោះអាចស្វែងរកចំណីបានគ្រប់គ្រាប់ ដែលអាចបញ្ជាក់បានតាមរយៈការពិនិត្យមើលផ្ទាល់ទៅលើលក្ខខ័ណ្ឌដងខ្លួន។ |

ទោចគួរត្រូវបានកំណត់ដឹងពីទីតាំងឲ្យបានញឹកញាប់ តាមដែលអាចធ្វើទៅបាន ក្នុងរយៈពេលយ៉ាងហោចណាស់ ១ឆ្នាំ ឬរហូតដល់ពួកគេមានបទពិសោធគ្រប់គ្រាន់រាល់គ្រប់រដូវកាលនៅក្នុងព្រៃ។ បន្ទាប់ពីនេះ ទីតាំងនោះនឹងត្រូវបានសិក្សាជាប្រចាំ ដើម្បីស្វែងយល់ពីទិសដៅ/ស្ថានភាពនៃចំនួនសត្វច្រើនឆ្នាំបន្តទៀត។ យើងកំណត់បានពីភាពជោគជ័យនៃការបម្លាស់ទី ដោយទោចក្នុងជំនាន់១អាចរស់រាន និងបង្កើតបានកូនមួយដែលកូនទោចនោះរស់នៅជាមួយម្តាយរហូតដល់ផ្តាច់ដោះ ដែលនេះគឺជាឱកាសរស់រាន និងបន្តពូជនៅក្នុងព្រៃមានលក្ខណៈដូចគ្នាទៅនឹងទោចដទៃ។ ដូច្នេះ ទិន្នន័យអំពីកូនទោចដែលកើតមក និងកំពុងរស់រាននេះក៏នឹងផ្តល់នូវព័ត៌មានពីភាពល្អប្រសើរនៃទោចដែលបានដោះលែង និងកំពុងតែលូតលាស់ធំធាត់ ជាជោគជ័យមួយដែលផ្អែកលើការបង្កើត ឬបង្កើនចំនួន ក៏ដូចជាភាគរយដែលទោចអាចរស់រានមានជីវិត។ ទន្ទឹមនឹងនោះ ភាពបរាជ័យក៏តែងតែកើតមានផងដែរ។

## ការដោះលែងបែបបម្លាស់ទីពីព្រៃមួយទៅព្រៃមួយ

ការដោះលែងបែបបម្លាស់ទីពីព្រៃមួយទៅព្រៃមួយនឹងត្រូវបានគ្រប់គ្រងយ៉ាងយកចិត្តទុកដាក់ ខុសប្លែកពីការដោះលែងបម្លាស់ទីបែបអភិរក្ស ដោយសារភាពឆាប់រហ័សដែលតម្រូវធ្វើឡើង និងខ្វះខាតតម្រូវការសម្រាប់ដំណើរការបម្សាំ។

- ភស្តុតាងថ្មីៗពីប្រទេសឥណ្ឌា និងឥណ្ឌូនេស៊ីបង្ហាញថា ការដោះលែងភ្លាមៗ (Hard-release) ជាធម្មតា គឺមានលក្ខណៈសមស្របចំពោះវិធីសាស្រ្តបម្លាស់ទីសត្វទោចពីព្រៃមួយទៅព្រៃមួយផ្សេងទៀតភ្លាមៗ។ ប៉ុន្តែ យោងតាមការសិក្សាពីប្រទេសថៃបង្ហាញថា វិធានការផ្តល់ឲ្យបន្ថែមតាមវិធីសាស្រ្តដោះលែងដោយមានការគាំទ្រ (Soft-release) គឺមានសារសំខាន់ ដើម្បីឲ្យការដោះលែងមួយទទួលបានជោគជ័យចំពោះទោចដែលត្រូវបម្លាស់ទី និងស្តារលទ្ធភាពឡើងវិញ(Brockelman and Osterberg 2015)។

ការជ្រើសរើសទីតាំងបម្លាស់ទីគួរតែមានលក្ខណៈដូចគ្នា ចំពោះទោចដែលត្រូវបម្លាស់ទី (សូមមើលផ្នែក **ការវាយតម្លៃទីតាំងដោះលែង**)។

- នៅពេលធ្វើការជ្រើសរើសទីជម្រកសមស្របដើម្បីដោះលែងទោច គួរតែយកចិត្តទុកដាក់ពីចម្ងាយទៅកាន់ទីតាំងថ្មីដើម្បីដឹងពីរយៈពេលដឹកជញ្ជូន។
- សត្វទោចគួរតែត្រូវបានដោះលែង យ៉ាងហោចណាស់ នៅក្នុងទំហំដែនមធ្យមមួយដើម្បីឲ្យសត្វប្រភេទនេះអាចស្ថិតនៅឆ្ងាយល្មមពីគ្រួសារទោចផ្សេងទៀតដែលរស់នៅក្បែរតាំងដោះលែងនោះ។

ការត្រួតពិនិត្យក្រោយដោះលែងគួរតែអនុវត្តឲ្យដូចគ្នាទៅនឹងវិធីសាស្រ្តដោះលែងបែបអភិរក្ស (សូមមើលសង្ខេបអំពី **ការត្រួតពិនិត្យក្រោយដោះលែង**)។

- ឧបករណ៍តាមដានដែលបំពាក់លើទោចគួរត្រូវបានយកចិត្តទុកដាក់ខ្ពស់ចំពោះការដោះលែង ដោយសារវាអាចធ្វើឲ្យខូចរោម (សូមមើលសង្ខេបអំពី **ការត្រួតពិនិត្យក្រោយដោះលែង**)។

## មែកធាងនៃការសម្រេចចិត្ត

ការធ្វើផែនការគឺជាគន្លឹះដើម្បីឲ្យគម្រោងជួយសង្គ្រោះ ស្តារលទ្ធភាពឡើងវិញ និងបម្លាស់ទីមានប្រសិទ្ធិភាពខ្ពស់ និងទទួលបានជោគជ័យ។ បញ្ហាដែលត្រូវបានបង្ហាញក្នុងអំឡុងពេលធ្វើផែនការ រួមមាន៖ ១-ផែនការបម្លាស់ទី និងវង្វាយតម្លៃហានិភ័យ ២-វត្ថិករវិទ្យា និងទីតាំងភូមិសាស្ត្ររបស់សត្វទោច ៣-ផែនការបច្ចេកទេស ៤-តម្រូវការចំពោះផែនការបច្ចេកទេស ៥-តម្រូវការចំពោះវិធីសាស្ត្រពហុវិន្និច្ឆ័យ និងយុទ្ធសាស្ត្រគ្រប់គ្រងបន្សាំ។ មែកធាងនៃការសម្រេចចិត្តខាងក្រោមត្រូវបានកែសម្រួលសម្រាប់អនុវត្តន៍ចំពោះប្រភេទស្វាធំ (Beck et al. 2007) ។

| | | |
|---|---|---|
| **ក១** | តើមានតម្រូវការចំពោះការធ្វើបម្លាស់ទីដែរឬទេ? ឧ-តើការបម្លាស់ទីអាចបង្កើតឡើងវិញឬពង្រឹងនូវចំនួនសត្វព្រៃឲ្យមានលំនឹងឬនៅថេរដោយខ្លួនឯងដើម្បីជម្រុញដល់ការរស់រាននៃចំនួនសត្វក្នុងអំបូរមួយបានយូរអង្វែង ឬក៏ជួយស្តារឡើងវិញនូវដំណើរការឬមុខងារនៃប្រព័ន្ធអេកូឡូស៊ីជាតិឬទេ? | ប្រសិនបើទេ បញ្ឈប់! |
| **ក២** | តើរាល់ច្បាប់ និងបទបញ្ញត្តិថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់អន្តរជាតិអាចនឹងត្រូវបំពេញដែរឬទេ? | កែប្រែផែនការរបស់អ្នកដើម្បីបំពេញនូវលក្ខខ័ណ្ឌច្បាប់ និងបទបញ្ញត្តិ និងបន្តទៅជំហាន ក៣ ឬក៏បញ្ឈប់ផែនការបម្លាស់ទីតែម្តង។ |
| **ក៣** | តើការបម្លាស់ទីគឺជាវិធីសាស្ត្រដ៏មានប្រសិទ្ធិភាព និងឆាប់រហ័សជាងគេចំពោះបម្លាស់ទីនៃអំបូរសត្វមួយប្រភេទនៅក្នុងអាណត្តិនៃអង្គការរបស់អ្នកឬ? | ប្រសិនបើមូលនិធីគឺជាកាពជាក់លាក់នៃបម្លាស់ទី សូមបន្តទៅ ក៤។ ប្រសិនបើមិនមែនទេ សូមពិចារណាមើលថាតើការអន្តរាគមន៍អភិរក្សផ្សេងទៀត (ឧ-ការពង្រឹង ការរឹបអូសការអភិវឌ្ឍគោលការណ៍ហេដ្ឋារចនាសម្ព័ន្ធដែនជម្រក) អាចផ្តល់នូវអត្ថប្រយោជន៍ ភ្លាមៗបន្ថែមទៀត សម្រាប់ការរស់រាននៃអំបូរសត្វក្នុងរយៈពេលវែងបានឬយ៉ាងណា។ |
| **ក៤** | តើអ្នកជំនាញ ក្រុមការងារពហុវិន្ញូវិយ មានតួនាទីធ្វើផែនការ និងណែនាំពីបម្លាស់ទីឬ? ឧ-អ្នកសិក្សាអំពីសត្វទោច បសុពេទ្យ អ្នកជំនាញផ្នែករុក្ខសាស្ត្រ អ្នកគ្រប់គ្រងបច្ចេកទេស និងហិរញ្ញវត្ថុ (មុខតំណែងទាំងអស់នេះមិនស៊ីជម្រៅ ឬមចំណែកបានទាំងស្រុងនោះទេ)។ | បង្កើតក្រុមការងាររបស់អ្នកដើម្បីបន្តទៅជំហាន ក៥ ឬបញ្ឈប់ផែនការបម្លាស់ទី។ |
| **ក៥** | តើមានសំណើសរសេរជាលាយលក្ខអក្សរដែលលម្អិតអំពីប្រវត្ត កម្មវត្ថុ មធ្យោបាយ វាយតម្លៃហានិភ័យ កាលបរិច្ឆេទ និងថវិការបស់គម្រោងដែរឬទេ? តើមានការបកស្រាយអំពីចំណេះដឹងពាក់ព័ន្ធនឹងបរិស្ថានសង្គម ឥរិយាបថ និងជីវវេជ្ជសាស្ត្រនៃប្រភេទសត្វឬយ៉ាងណា? | បកស្រាយគោលគំនិតក្នុងអក្សរសាស្ត្ររបស់អ្នក និងបន្តទៅជំហាន ក៦ ឬបញ្ឈប់ផែនការបម្លាស់ទី។ |
| **ក៦** | តើមានទីតាំងដោះលែងដ៏សមស្រប និងមានសក្តានុពលនៅក្នុងតំបន់ដែលជាដែនជម្រកដើមរបស់ប្រភេទសត្វនេះឬទេ? | បញ្ឈប់ផែនការម្លាស់ទី ឬពិចារណាមើលថាការណែនាំអំពីការអភិរក្សចាំបាច់ដែរឬទេ។ |
| **ក៧** | តើមានប្រភេទសត្វបង្ហាញខ្លួននៅទីតាំងដែលបានសិក្សាឬទេ? វត្តមាននៃសត្វប្រភេទនោះត្រូវបានកំណត់ដោយប្រើនូវវិធីសាស្ត្រសិក្សាតាមបែបស្តង់ដារ(មើលគោលការណ៍អនុវត្តន៍ប្រកបដោយប្រសិទ្ធិភាពខ្ពស់អំពីការសិក្សា និងការត្រួតពិនិត្យសត្វទោច)។ | បន្តទៅជំហាន ក៩។ |
| **ក៨** | តើចំនួននៃប្រភេទសត្វទាមទារឲ្យមានការពង្រឹងដែរឬទេ? ការទាមទារនូវការពង្រឹងនេះគឺចាំបាច់ត្រូវធ្វើការវាយតម្លៃតាមរយៈមធ្យោបាយផ្លូវការមួយចំនួនដែលរួមមានការសិក្សាប្រភេទសត្វ និងការវិភាគពីលទ្ធភាពដែលអាចសម្រេចបាន។ | បញ្ឈប់ផែនការបម្លាស់ទីក្នុងផ្នែកនោះ។ |
| **ក៩** | តើមានការវាយតម្លៃទីតាំងពេញលេញដើម្បីកំណត់ថាតើទីតាំងនោះមានលក្ខខ័ណ្ឌសមស្របឬមិនសមស្របពាក់ព័ន្ធទៅនឹងកម្មសិទ្ធិដីធ្លី ដែនជម្រក វត្តមានចំណីអាហារ ការការពារ និងដំណើរការសម្រេចចិត្តរួមគ្នា រវាងអង្គភាពពាក់ព័ន្ធគម្រោងនៅក្នុងតំបន់ឬទេ? | ធ្វើការវាយតម្លៃទីតាំង។ |

**ក១០** តើប្រភពដើមដែលជាមូលហេតុបង្កឲ្យមានការធ្លាក់ចុះ និងផុតពូជប្រភេទសត្វត្រូវបានយកចិត្តទុកដាក់ និងដោះស្រាយដែរឬទេ?

→ ប្រសិនបើទេ សូមបង្ហាញនូវប្រភពដើមដែលជាមូលហេតុនៃការធ្លាក់ចុះ និងបន្ទាប់មកបន្តទៅជំហាន ក១១ ឬក៏បញ្ឈប់ផែនការបម្លាស់ទី។

**ក១១** តើមានការធានានូវឱកាសជំរុញហេតុផលមួយ មូលនិធិរយៈពេលវែងសម្រាប់គម្រោងបម្លាស់ទី រួមទាំងការរៀបចំយ៉ាងត្រឹមត្រូវនៃទោចដែលនឹងត្រូវដោះលែង និងការត្រួតពិនិត្យក្រោយដោះលែងរយៈពេលវែងឬទេ?

→ ស្វែងរក និងធានានូវមូលនិធិគ្រប់គ្រាន់ និងបន្តទៅជំហាន ក១២ ឬបញ្ឈប់ផែនការបម្លាស់ទី។

**ក១២** តើរដ្ឋាភិបាលនៅថ្នាក់ជាតិ និងស្រុក/ខ័ណ្ឌ ធ្វើការនៅក្នុងដែនសមត្ថកិច្ចដែលទីតាំងដោះលែងត្រូវបានកំណត់ បានគាំទ្រដល់ការបម្លាស់ទីនេះដែរឬទេ? ហើយមានការគាំទ្រពីសហគមន៍ក្នុងតំបន់ដែរឬយ៉ាងណា?

→ កសាងការសម្រេចចិត្តរួមគ្នាសម្រាប់ការបម្លាស់ទី និងបន្តទៅជំហាន ក១៣ ឬបញ្ឈប់ផែនការបម្លាស់ទី។

**ក១៣** តើទោចដែលត្រូវបម្លាស់ទីត្រូវបានវាយតម្លៃពីការអភិវឌ្ឍ និងឥរិយាបថឬទេ? ពួកគេទាមទារនូវជំនាញក្នុងផ្នែកអេកូឡូស៊ី និងផ្នែកសង្គមធម្មជាតិឬអត់? ហើយពួកគេបានផ្ដាច់ទំនាក់ទំនង និងការពឹកពាក់ពីមនុស្ស ដែលអាចរស់នៅដោយឯករាជ(ឬជាមួយនឹងភាពឯករាជពិតប្រាកដ)នៅក្នុងព្រៃ-ត្រូវបានស្តារលទ្ធភាពឡើងវិញឬ?

→ ធ្វើការវាយតម្លៃ បណ្ដុះបណ្ដាល និងអភិវឌ្ឍស្តារលទ្ធភាពឡើងវិញ និងបន្តទៅជំហាន ក១៤ ឬបញ្ឈប់ផែនការបម្លាស់ទី។

**ក១៤** តើសត្វទោចដែលត្រូវដោះលែងត្រូវបានកំណត់ប្រភេទ ឬអនុប្រភេទ យោងតាមប្រព័ន្ធកំណត់ និងឲ្យឈ្មោះប្រភេទសត្វបច្ចុប្បន្ន ដោយប្រើវិធាយតម្លៃទៅលើរូបសាស្ត្រ ឥរិយាបថ និង/ឬហ្សែនដើម្បីធានាថា ពួកគេស្ថិតក្នុងប្រភេទដែលដូចគ្នាទៅនឹងប្រភេទដែលធ្លាប់មានពីមុនមក ឬប្រភេទដែលកំពុងរស់នៅទីតាំងដោះលែងនេះឬ?

→ ប្រសិនបើទេ សូមធ្វើការវាយតម្លៃរូបសាស្ត្រដើម្បីធានាភាពដូចគ្នានៃប្រភេទសត្វ និងបន្តទៅជំហាន ក១៥ ឬប្រសិនបើសត្វមិននៅក្នុងប្រភេទដូចគ្នាទេនោះ សូមត្រឡប់ទៅជំហាន ក១វិញ ឬបញ្ឈប់ផែនការបម្លាស់ទី។

**ក១៥** តើទោចដែលត្រូវបម្លាស់ទីបានទទួលការពិនិត្យ និងធ្វើតេស្ត ដាក់នៅដោយឡែក ព្យាបាល និងចាក់ថ្នាំបង្ការ សម្រាប់ដោះលែងហើយឬនៅ?

→ ប្រសិនបើនៅ សូមដាក់ទោចនៅទីតាំងដាច់ដោយឡែក និងព្យាបាលពួកគេ បន្ទាប់មកបន្តទៅជំហាន ក១៦ ឬបញ្ឈប់ផែនការបម្លាស់ទី។

**ក១៦** តើមានផែនការដឹកជញ្ជូនទោចទៅកាន់ទីតាំងដោះលែងដោយសុវត្ថិភាព និងផែនការដោះលែងពួកគេហើយឬនៅ?

→ ប្រសិនបើនៅ សូមរៀបចំផែនការរបស់អ្នកឲ្យបានច្បាស់លាស់ និងបន្តទៅជំហាន ក១៧ ឬបញ្ឈប់ផែនការបម្លាស់ទី។

**ក១៧** តើគោលការណ៍បង្ការទុករអាចនឹងត្រូវប្រកាន់ខ្ជាប់ដែរឬទេ?

→ បញ្ឈប់ផែនការបម្លាស់ទី។

**ក១៨** ដោះលែងទោច ចាប់ផ្ដើមដំណើរការគ្រប់គ្រង និងត្រួតពិនិត្យក្រោយដោះលែង។ បន្តទៅជំហាន ក១៩ ។

**ក១៩** រៀបចំជាឯកសារ និងផ្សព្វផ្សាយលទ្ធផលក្រោយដោះលែង។ ១៩

( **បកប្រែក្រៅផ្លូវការ** )

## References


Brockelman, W. Y., & Ali, R. (1987). Methods of surveying and sampling forest primate populations. In R. A. Mittermeier & R. W. Marsh (Eds.), *Primate Conservation in the tropical rainforest.* (pp. 23–62). New York: Alan Liss.

Brockelman, W. Y., & Srikosamatara, S. (1993). Estimation of Density of Gibbon Groups by Use of Loud Songs. *American Journal of Primatology*, *29*(1), 93–108.

Campbell, C. O., Cheyne, S. M., & Rawson, B. . (2015). *Best Practice Guidelines for the Rehabilitation and Translocation of Gibbons*. Gland, Switzerland.

Carlstead, K., Seidensticker, J. C., & Baldwin, R. (1991). Environmental enrichment for zoo bears. *Zoo Biology*, *10*, 3–16.

Chetry, D., Chetry, R., & Bhattacharjee, P. C. (2007). *Hoolock, The Ape of India*. Mariani, Assam, India: Gibbon Conservation Centre and Gibbon Wildlife Sanctuary.

Cheyne, S. M. (2005). Re-introduction of captive-raised gibbons in Central Kalimantan, Indonesia. *Reintroduction News*, *24*, 22–25.

Cheyne, S. M. (2009a). Challenges and Opportunities of Primate Rehabilitation – Gibbons as a Case Study. In K. A. I. Nekaris, V. Nijman, M. Bruford, J. Fa, & B. Godley (Eds.), *Primate Conservation: Measuring and mitigating trade in primates*. Endangered Species Research.

Cheyne, S. M. (2009b). The Role of Reintroduction in Gibbon Conservation: Opportunities and Challenges. In S. M. Lappan, D. L. Whittaker, & T. Geissmann (Eds.), *The Gibbons: New Perspectives on Small Ape Socioecology and Population Biology* (pp. 477–496). New York: Springer.

Cheyne, S. M., Campbell, C. O., & Payne, K. L. (2012). Proposed guidelines for gibbon rehabilitation and reintroduction. *International Zoo News*, *46*, 1–17.

Cheyne, S. M., Chivers, D. J., & Sugardjito, J. (2008). Biology and Behaviour of Released Gibbons. *Biodiversity and Conservation*, *17*, 1741–1751.

Cheyne, S. M., Thompson, C. J. H., Phillips, A. C., Hill, R. M. C., & Limin, S. H. (2007). Density and Population Estimate of Gibbons (Hylobates albibarbis) in the Sabangau Catchment, Central Kalimantan, Indonesia. *Primates*, *49*(1), 50–56. doi:DOI: 10.1007/s10329-007-0063-0

Dickie, L. A. (1994). *Environmental Enrichment in Captive Primates: a survey and review*. University of Cambridge, Cambridge.

Hamard, M. C. L., Cheyne, S. M., & Nijman, V. (2010). Vegetation correlates of gibbon density in the peat-swamp forest of the Sabangau catchment, Central Kalimantan, Indonesia. *American Journal of Primatology*, *72*(7), 607–616. doi:10.1002/ajp.20815

Hebert, P. L., & Bard, K. (2000). Orang-utan use of vertical space in an innovative habitat. *Zoo Biology*, *19*, 239–251.

IUCN/SSC. (2013). *Guidelines for Reintroductions and other Conservation Translocations* (Version 1.). Gland, Switzerland: IUCN Species Survival Commission.

Kleiman, D. G. (1989). Reintroduction of captive mammals for conservation: guidelines for reintroducing endangered animals into the wild. *Bioscience*, *39*, 152–161.

Komdeur, J., & Deerenberg, C. (1997). The importance of social behavior studies for conservation. In J. . Clemmons & R. Buchholz (Eds.), *Behavioral approaches to conservation in the wild* (pp. 262–277). Cambridge (UK): Cambridge University Press.

Nijman, V., & Menken B.J., S. (2005). Assessment of census techniques for estimating density and biomass of gibbons (Primates: Hylobatidae). *The Raffles Bulletin of Zoology*, *53*(1), 169–179.

Reinhardt, V., & Smith, M. D. (1988). PVC pipes effectively enrich the environment of caged rhesus macaques. *Laboratory Primate Newsletter*, *27*(3), 4–5.

Smith, J. (2010). Reintroducing Javan gibbons (Hylobates moloch): An assessment of behavioral preparedness. *The Gibbon's Voice*, *12*(1), 2–7.